# បទបញ្ជា

# ស្តីពី

# ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា


I - សេចក្ដីផ្ដើម

១.សាវតារ

២.ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា

II - មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា

១.មុខងារ និងភារកិច្ច

២.រចនាសម្ព័ន្ធ

III - នីតិវិធីនៃការពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់

IV - ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា

V - ការចូលជាធរមាននៃច្បាប់

VI - ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

# I- សេចក្តីផ្តើម

## ១.សាវតារ

ក្រោយការបោះឆ្នោតសាកល ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ :

- កិច្ចប្រជុំថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយធំទាំងពីរ ដែលមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចព្រះបរមរតនកោដ្ឋ អតីតព្រះមហាក្សត្រ** បានឯកភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងបានចូលជាធរមាននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ។

- អនុលោមតាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ព្រឹទ្ធសភាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ។

## ២.ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា

ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និងបទដ្ឋានគតិយុត្តនានារបស់ព្រឹទ្ធសភា ។

### ក. ព្រឹទ្ធសភានីតិកាលទី១ ៖

- កើតឡើងដោយការតែងតាំង សម្រាប់រយៈពេល៥ឆ្នាំ
- សមាជិកសរុប មានចំនួន៦១រូប :
  - ប្រធាន និងអនុប្រធានទាំងពីរ តែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានរដ្ឋសភា

- ២រូបចាត់តាំងដោយព្រះមហាក្សត្រ
- សមាជិកដទៃទៀត តែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២ (គណបក្សប្រជាជនកម្ពុជា (CPP) ៣១រូប, គណបក្សហ៊្វុនស៊ីនប៉ិច (FUN) ២១រូប, គណបក្សសមរង្ស៊ី (SRP) ០៧រូប ) ។

➢ បើកសម័យប្រជុំលើកទី១ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩

➢ ប្រកាសបន្តនីតិកាលចំនួនពីរដង ម្តងមួយឆ្នាំ ។

## ខ. ព្រឹទ្ធសភានីតិកាលទី២ និងនីតិកាលបន្តបន្ទាប់ ៖

- កើតឡើងដោយការបោះឆ្នោតជាអសកលផង ចាត់តាំងផង និងជ្រើសតាំងផង សម្រាប់រយៈពេល៦ឆ្នាំ ។
- នីតិកាលទី២ និងនីតិកាលទី៣ មានសមាជិកសរុបចំនួន៦១រូប ។ ប៉ុន្តែនីតិកាលទី៤ សមាជិកព្រឹទ្ធសភាមានចំនួន៦២រូប ដូចខាងក្រោម ៖
  - ៥៨រូប ជ្រើសតាំងដោយការបោះឆ្នោតជាអសកល សម្រាប់៨ភូមិភាគ
  - ២រូប ចាត់តាំងដោយព្រះមហាក្សត្រ
  - ២រូប ជ្រើសតាំងដោយរដ្ឋសភា ។
- អង្គបោះឆ្នោត : ក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រទាំងអស់ក្នុងតំណែង ។

## II- មុខងារ តួនាទី និងរចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា

### ១.មុខងារ និងតួនាទី

ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ក្នុងនាមជាអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានមុខងារសំខាន់ៗ ដូចខាងក្រោម ៖

**ក- មុខងារនីតិកម្ម** ៖ ការពិនិត្យហើយឱ្យយោបល់ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ព្រឹទ្ធសភាត្រូវអនុវត្តន៍តាមបទប្បញ្ញត្តិមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ។

ជាទូទៅ ការពិនិត្យហើយឱ្យយោបល់ ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ។ គណៈកម្មការមានសិទ្ធិអញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ មកបំភ្លឺចំពោះមុខគណៈកម្មការបាន ។

**ខ. មុខងារតាមដានការអនុវត្តច្បាប់ ៖** ព្រឹទ្ធសភាមានគណៈកម្មការចំនួន១០ ទទួលខុសត្រូវតាមវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។ គណៈកម្មការនីមួយៗ បំពេញការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ច ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ គណៈកម្មការនីមួយៗ មានផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់ខ្លួន ។ នៅចន្លោះសម័យប្រជុំនីមួយៗ គណៈកម្មការត្រូវចុះទៅបំពេញមុខងារនេះ តាមក្រសួង មន្ទីរ រាជធានី ខេត្ត ដើម្បីពិនិត្យមើលការអនុវត្តច្បាប់ និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ។

ព្រឹទ្ធសភាពុំមានសិទ្ធិកោះអញ្ជើញសមាជិករាជរដ្ឋាភិបាល មកសួរដេញដោលចំពោះមុខគណៈកម្មការ ឬក្នុងសម័យប្រជុំពេញអង្គ លើបញ្ហាបច្ចុប្បន្នភាពណាមួយដូចរដ្ឋសភាឡើយ ។

**គ. មុខងារតំណាង ៖** សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។ ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគនីមួយៗ តែងចុះទៅប្រាស្រ័យទាក់ទងការងារដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងភូមិភាគរបស់ខ្លួន ដើម្បីរៀបចំវេទិកាថ្នាក់ភូមិភាគ ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយកំណត់នូវប្រធានបទបច្ចុប្បន្នភាពជាក់លាក់ និងបញ្ហាប្រឈមនានា ដើម្បីធ្វើការដោះស្រាយ ព្រមទាំងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេចនៅក្នុងសម័យប្រជុំបន្ទាប់ ។

ភាពជាតំណាងក្រុមប្រឹក្សាឃុំសង្កាត់ នាំឱ្យព្រឹទ្ធសភាមានបេសកកម្មផ្ទាល់របស់ខ្លួនក្នុងលក្ខណៈជាពិសេសមួយ ដោយត្រូវផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងកិច្ចការពារនិងលើកតម្កើងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស រួមទាំងភូមិភាគទាំង៨ទៀតផង ។ ដូច្នេះ ព្រឹទ្ធ-សភា មានកាតព្វកិច្ចចូលរួមចំណែកយ៉ាងខ្លាប់ខ្លួន ក្នុងការតាមដានមើលការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពោលគឺជួយជំរុញធ្វើឱ្យមានការអភិវឌ្ឍបានត្រឹមត្រូវ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

**ឃ. មុខងារសហប្រតិបត្តិការអន្តរជាតិ ៖** ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រឹទ្ធសភាបានបំពេញការងារយ៉ាងសកម្ម ក្នុងការចូលរួមអនុវត្តកាតព្វកិច្ចអន្តរជាតិ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសភា និងអង្គការអន្តរសភានានាក្នុងតំបន់ និងពិភពលោក ។ ក្នុងគ្រប់នីតិកាល ព្រឹទ្ធសភាបានចាត់ទុកកិច្ចសហប្រតិបត្តិការ អន្តរជាតិជាកម្លាំងស្នូលនៃការអភិវឌ្ឍស្ថាប័ន ។ ក្នុងនោះព្រឹទ្ធសភាបានបង្កើតឱ្យ មានក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាបណ្តាប្រទេសនានា មានចំនួន ១៥ក្រុម (បារាំង, វាឡូនី-ប្រ៊ុចសែល, ឡាវ, វៀតណាម, ចិន, ជប៉ុន, អូស្ត្រាលី និងញូវហ្ស៊ីលែន, ថៃឡង់ដ៍, ទួរគី, រុស្ស៊ី, ម៉ុងហ្គោលី, សាធារណៈរដ្ឋកូរ៉េ, ឥណ្ឌា, និងមីយ៉ាន់ម៉ា) និងក្រុមសមាជិកព្រឹទ្ធសភាពហុភាគី មានចំនួន ៧ក្រុម (ក្រុម AIPA, IPU, APF, CLV, APA, APPF, និង ASEP ) ។

**ង. មុខងារ អភិវឌ្ឍស្ថាប័ន ៖** ព្រឹទ្ធសភា មានមោទនភាពលើសមិទ្ធផលជាស្នាដៃ នៃការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន គួបផ្សំនឹងកិច្ចសហប្រតិបត្តិការដ៏មានតម្លៃ ទាំង ពហុរូបភាព និងពហុវិស័យ ដែលមិនអាចខ្វះបានពីដៃគូអភិវឌ្ឍន៍នានា បានជំរុញឱ្យព្រឹទ្ធសភា ពង្រឹងបាននូវសមត្ថភាព ទាំងផ្នែកធនធានមនុស្ស មធ្យោបាយ សម្ភារ បរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

# ២.រចនាសម្ព័ន្ធ


ប្រធានព្រឹទ្ធសភា
អនុប្រធានទី១
អនុប្រធានទី២
គណៈកម្មាធិការអចិន្ត្រៃយ៍
គណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យ បណ្ដឹង និង អង្កេត
១
គណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម
២
គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ ជនបទ និង បរិស្ថាន
៣
គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារ សាធារណៈ
៤
គណៈកម្មការ កិច្ចការ បរទេស សហប្រតិបត្តិការ អន្តរជាតិ ឃោសនាការ និងព័ត៌មាន
៥
គណៈកម្មការ នីតិកម្ម និង យុត្តិធម៌
៦
គណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រ សិល្បៈ និង ទេសចរណ៍
៧
គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី
៨
គណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
៩
គណៈកម្មការ អង្កេត បោសសម្អាត និង ប្រឆាំងអំពើពុករលួយ
១០

គណៈកម្មការនានារបស់ព្រឹទ្ធសភា គឺជាយន្តការស្នូលជួយទ្រទ្រង់ដល់ដំណើរការអនុវត្តមុខងាររបស់ព្រឹទ្ធសភា ក្នុងនាមជាកូនព្រឹទ្ធសភា (Mini-sénats) មានតួនាទីជាសេនាធិការក្នុងការបំពេញមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ព្រមទាំងជានាប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ច ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភាទាំងមូល ។

គណៈកម្មការនានារបស់ព្រឹទ្ធសភា មានភារកិច្ចពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន ។

ក្រៅពីគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា និងគណៈកម្ម-ការពិសេស ព្រឹទ្ធសភាមានក្រុមផ្សេងៗ ដែលបានបង្កើតឡើងតាមបញ្ញត្តិប្រការ១១ថ្មី និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដូចខាងក្រោម ៖

១.ក្រុមសមាជិកព្រឹទ្ធសភា មាន ៥ក្រុម ។

២.ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ មាន ៨ក្រុម ។

៣.ក្រុមសមាជិកាព្រឹទ្ធសភា មាន ១ក្រុម ។

៤.ក្រុមមិត្តភាពជាមួយសភាបណ្ដាប្រទេសនានា មាន ១៥ក្រុម ។

៥.ក្រុមអង្គការអន្តរសភា មាន ៧ក្រុម (ក្រុម AIPA, IPU, APF, CLV, APA, APPF, និង ASEP ) ។

៦.ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ មាន ១ក្រុម ។

៧.គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា មាន ១ក្រុម ។

ក្រុមទាំងនេះ ដំណើរការការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងមានរបបថវិកាប្រចាំខែសម្រាប់ដំណើរការការងារ ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

## III-នីតិវិធីនៃពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់

ការពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងរបស់ព្រឹទ្ធសភា ប្រព្រឹត្តទៅស្របតាមមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម ៖

១. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យ និងសម្រេចលើសំណើរបស់រដ្ឋសភា ដើម្បីចាត់បញ្ជូនទៅគណៈកម្មការទទួលបន្ទុក ពិនិត្យសិក្សាតាមវិស័យជាសមត្ថកិច្ច ។

២. គណៈកម្មការទទួលបន្ទុក ត្រូវពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ តាមនីតិវិធីដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

៣. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទទួលបន្ទុកសុំដាក់បញ្ចូលទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា ។

៤. ប្រជុំព្រឹទ្ធសភា ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ។

# គំនូសបំព្រួញ អំពីនីតិវិធីក្នុងការពិនិត្យ និងអនុម័តរវាងរដ្ឋសភា និងព្រឹទ្ធសភា



# IV- ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា

## មាត្រា១១៣ថ្មី រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**រដ្ឋសភា**

សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលបានអនុម័ត

**ព្រឹទ្ធសភា**

- ៣០ថ្ងៃ (ច្បាប់ធម្មតា)
- ៥ថ្ងៃ (ច្បាប់ប្រញាប់)

ប្រសិនបើព្រឹទ្ធសភាឱ្យយោបល់យល់ព្រម ឬពុំបានផ្ដល់យោបល់សោះក្នុងរយៈពេលដែលបានកំណត់ទុក ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រម នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

# មាត្រា១១៣ ថ្មី វាក្យខណ្ឌទី៣ វាក្យខណ្ឌទី៤ និងវាក្យខណ្ឌទី៥

**រដ្ឋសភា**

ការពិនិត្យលើកទី២ ៖ ទទួល ឬបដិសេធទាំងស្រុង ឬដោយផ្នែក

១ខែ (ច្បាប់ធម្មតា)

១០ថ្ងៃ (ច្បាប់ថវិកា)

២ថ្ងៃ (ប្រញាប់)

**ព្រឹទ្ធសភា**

ស្នើឱ្យរដ្ឋសភាកែសម្រួល

ពេលវេលានៃសភាទាំងពីរអាចបន្ថែមឱ្យស្មើគ្នា ប្រសិនបើរដ្ឋសភាទុកឱ្យលើស ឬបន្ថែមលើរយៈពេលដែលបានកំណត់ដូចខាងលើ (ការបង្វិលទៅបង្វិលមកតាមបិរវេលាកំណត់ រហូតដល់មានការស្រុះស្រួល ឯកភាពគ្នា)

# ក្នុងករណីដែលព្រឹទ្ធសភាបដិសេធ

(មាត្រា១១៣ ថ្មី វាក្យខណ្ឌទី៦ និងទី៧)

**រដ្ឋសភា**
មិនអាចយកមកពិចារណាជាលើកទី២

[១] មុន ១ ខែ (ច្បាប់ធម្មតា)

[២] មុន ១៥ ថ្ងៃ (ច្បាប់ថវិកា)

[៣] មុន ៤ ថ្ងៃ (ច្បាប់ប្រញាប់)

**ព្រឹទ្ធសភា**
បដិសេធចោលច្បាប់ដែលរដ្ឋសភាបានអនុម័ត

បន្ទាប់ពីរយៈពេលកំណត់នេះ រដ្ឋសភាយកមកពិចារណាជាលើកទី២ ហើយអនុម័តសេចក្ដីព្រាង ឬសេចក្ដីស្នើច្បាប់ដោយបោះឆ្នោតចំហរ ជាមួយសំឡេងអនុម័តភាគច្រើនដាច់ខាត ។

## V- ការចូលជាធរមាននៃច្បាប់

រដ្ឋសភា ពេលទទួលបានយោបល់យល់ព្រមលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ពីព្រឹទ្ធសភា ត្រូវបញ្ជូនទៅរាជរដ្ឋាភិបាល ដើម្បីបន្តនីតិវិធីបង្គំទូលថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ ។

មាត្រា២៨ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ចែងថា «**ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី**» ។

មាត្រា៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា «ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស ក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ » ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលវេលាកំណត់ខាងលើ ។

## VI- ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធសភា មានអត្តសញ្ញាណខុសគ្នា ដូចខាងក្រោម ៖

| រដ្ឋសភា | ព្រឹទ្ធសភា |
|---|---|
| - <u>ចំនួន</u> : សមាជិកយ៉ាងតិច១២០រូប (មាត្រា៧៦ថ្មី នៃរដ្ឋធម្មនុញ្ញ) | - <u>ចំនួន</u> : សមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល (មាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញ) |
| - <u>ការជ្រើសតាំង</u> : បោះឆ្នោតជាសកល | - <u>ការជ្រើសតាំង</u> : បោះឆ្នោតជាអសកលផង ចាត់តាំងផង និងជ្រើសតាំងផង |
| - <u>នីតិកាល</u> : ៥ឆ្នាំ | - <u>នីតិកាល</u> : ៦ឆ្នាំ |
| - <u>បេក្ខជន</u> : អ្នកមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត | - <u>បេក្ខជន</u> : អ្នកមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត |

| | |
|---|---|
| - អ្នកបោះឆ្នោត : អ្នកមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច១៨ឆ្នាំ | - អង្គបោះឆ្នោត : តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង |
| - មណ្ឌលបោះឆ្នោត : រាជធានី ខេត្ត | - មណ្ឌលបោះឆ្នោត : ភូមិភាគទាំង៨ |
| - បោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល សួរដេញដោល ដាក់ញត្តិបន្ទោស និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល | - សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋា-ភិបាល ដែលជាតួនាទីនយោបាយ |
| - អាចត្រូវបានរំលាយមុនផុតនីតិកាល បើសិនរាជ-រដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដង ក្នុងរយៈពេល ១២ខែ (មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ) ។ | - មិនអាចរំលាយមុនផុតនីតិកាលបានឡើយ ។ |


ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំវិសាមញ្ញ


ព្រឹទ្ធសភាកម្ពុជា
ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំវិសាមញ្ញ

# សូមអរគុណ